**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍**

**សំណុំរឿងព្រហ្មទណ្ឌ**

លេខៈ១៩៣/០៦-៤-២០០៩

**សាលដីកា**

លេខៈ៨៦(ច)/២៩-១២-២០០៩

# តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខៈ០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី២៩-១២-២០០៩ ដែលមានសមាសភាពដូចតទៅ :

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខៈ១៩៣ ចុះថ្ងៃទី០៦-៤-២០០៩ រវាង :

១-ជនជាប់ចោទឈ្មោះ [redacted] ស្លេម៉ាន ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរកម្មករសំណង់ កើតនៅភូមិកំពង់យោល ឃុំកំពង់យោល ស្រុកកំពង់យោល ខេត្តតាកែវ ទីលំ[redacted] ក្រុម៧ ភូមិ៣ សង្កាត់ជ្រោយចង្វា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]ស) ម្តាយឈ្មោះ [redacted]) នៅលីវ ទោសពីមុនគ្មាន ។

ចាប់ខ្លួនថ្ងៃទី០៨-១២-២០០៧ ឃុំខ្លួនថ្ងៃទី១១-១២-២០០៧ ។

២-ជនជាប់ចោទឈ្មោះ[redacted]ម៉ូស្លឹម ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរនៅផ្ទះ កើតនៅសង្កាត់ជ្រោយចង្វា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទីលំនៅស[redacted] ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោ[redacted](រ) ប្រពន្ធឈ្មោះ [redacted] ទោសពីមុនគ្មាន ។

ចាប់ខ្លួនថ្ងៃទី០៨-១២-២០០៧ ឃុំខ្លួនថ្ងៃទី១១-១២-២០០៧ ឃុំខ្លួននៅពន្ធនាគារព្រៃស១ ។

មេធាវីការពារឈ្មោះ [redacted] សុខា

ត្រូវជាប់ចោទពីបទ:__ប្លន់(លួចមានគួកន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៨-១២-២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារីស៊ំ ភេទស្រី អាយុ៤៩ឆ្នាំ ជាតិចាម ទីលំនៅសព្វថ្ងៃភូមិស៊ីដា ឃុំស៊ីដា ស្រុកដំបែរ ខេត្តកំពង់ចាម ។

តាមពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៤-១០-២០០៨ របស់ឈ្មោះ [redacted] មូស្លឹម ប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ:៤៩(ក្រ៥) ចុះថ្ងៃទី២៥-៩-២០០៨ របស់សាលាដំបូងក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## អង្គហេតុមានដូចតទៅ

នៅយប់ថ្ងៃទី០៧-១២-២០០៧ ជនល្មើសឈ្មោះ [redacted] ស្លេម៉ាន, ឈ្មោះ [redacted] មូស្លឹម និង ជនមិនស្គាល់មុខជនជាតិវៀតណាម បាននាំគ្នាចូលលួចទ្រព្យសម្បត្តិជនរងគ្រោះឈ្មោះ [redacted] សារីស៊ំ ក្នុងពេលជនរងគ្រោះ និង ក្រុមគ្រួសារកំពុងដេកលក់ ដោយក្រុមជនល្មើសបានលួចយកគ្រឿងអលង្ការ ទូរស័ព្ទ និង ប្រេងចំនួន៣កាដុង ហើយយកទៅលក់ឱ្យ [redacted] ស្មុះតីអ៊ី តែឈ្មោះ [redacted] ស្មុះតីអ៊ី មិនទិញ លុះនៅថ្ងៃទី០៨-១២-២០០៧ សមត្ថកិច្ចឃាត់ខ្លួនឈ្មោះ [redacted] ស្លេម៉ាន និងឈ្មោះ [redacted] មូស្លឹម បានតែម្តង ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] មូស្លឹម ឆ្លើយថា: កាលពីថ្ងៃទី០៨-១២-២០០៧ វេលាម៉ោងប្រហែល២យប់ ខ្លួននិងមិត្តភ័ក្រ្តឈ្មោះ [redacted] ស្លេម៉ាន បានអុំទូកដើររកត្រី លុះអុំដល់ផែបូមខ្សាច់ហៅផែឈ្លូន ខ្លួនបានលួចយកប្រេងម៉ាស៊ូតពីលើផែឈ្លូននោះបានចំនួន៣ធុង រួចហើយខ្លួន និងឈ្មោះ ស្លេម៉ាន បានអុំទូកយកប្រេងនោះមកលក់ឱ្យឈ្មោះ [redacted] ស្មុះតីអ៊ី តែមិនទាន់បានលុយឡើយ ព្រោះគាត់គ្មានលុយគ្រប់ ។ ខ្លួនក៏បានខ្ចីគាត់មួយម៉ឺនរៀលសិន រួចទាំងពីរនាក់ត្រឡប់មកដេកវិញ ។ លុះព្រឹកឡើងម្ចាស់ប្រេងបានចូលទៅកោសខ្យល់នៅផ្ទះ [redacted] ស្មុះតីអ៊ី គាត់បានឃើញធុងប្រេងនោះ គាត់ក៏បានប្តឹងសមត្ថកិច្ចឱ្យចាប់ខ្លួនតែម្តង ។ ខ្លួនសូមបញ្ជាក់ថាប្រេងដែលខ្លួនលួចនោះពុំមែនជាប្រេងរបស់ដើមបណ្តឹងទេ ម្ចាស់ប្រេងពិតប្រាកដគេមិនប្តឹងខ្លួនឡើយ ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ស្លេម៉ាន ឆ្លើយថា: កាលពីថ្ងៃទី០១-២-២០០៧ វេលាម៉ោងប្រហែល២យប់ ខ្លួននឹងឈ្មោះ [redacted] មូស្លឹម បានអុំទូកទៅកាន់ផែបូមខ្សាច់ ហៅ ផែឈ្លូន ។ នៅពេលទៅដល់ខ្លួននិង [redacted] មូស្លឹម បានលួចយកប្រេងម៉ាស៊ូតពីផែនោះបានចំនួន៣ធុង ដាក់លើទូកដែលខ្លួនអុំទៅ ពេលលួចបានហើយ ខ្លួនបានយកទៅលក់ឱ្យឈ្មោះ [redacted] ស្មុះតីអ៊ី ដែលមានផ្ទះនៅក្បែរគ្នា ។ លុះស្អែកឡើងម្ចាស់ប្រេងបានចូលទៅកោសខ្យល់ ក៏បានឃើញធុងប្រេងដែលខ្លួនលួចនោះ ។ ម្ចាស់ប្រេងក៏ប្តឹងឱ្យគេចាប់ខ្លួនតែម្តង ។

-តាមចម្លើយដើមបណ្តឹងឈ្មោះ [redacted] សារីស៊ំ ឆ្លើយថា: កាលពីថ្ងៃទី០៧-១២-២០០៧ វេលាម៉ោងប្រហែល៩យប់ ខ្លួនបានចូលសំរាកក្នុងកាណូត ដោយយកគ្រឿងអលង្ការដាក់ក្នុងប្រអប់ ហើយយកអាវរងារុំពីក្រៅ រួចដេកអោបជាប់នឹងខ្លួនជារៀងរាល់រាត្រី ព្រមទាំងមានកាបូបយួរមួយទៀតដែលមានទូរស័ព្ទ០២គ្រឿង នៅក្នុងកាបូបនោះដែរ ។



Scanned with CamScanner

ពេលខ្លួនដេកលក់ម៉ោងប្រហែល៣ទៀបភ្លឺ ក្នុងថ្ងៃ០៨-១២-២០០៧ ខ្លួនក្រោកពីដេក ស្រាប់តែបាត់សំភារៈទាំងនោះអស់តែម្តង ហើយមានបាត់ប្រេងម៉ាស៊ូតចំនួន១៤កាន ចំនួន៤២០លីត្រ ។ ចំណែកគ្រឿងអលង្ការដែលបាត់នោះមានខ្សែកមាសមួយខ្សែទំងន់២តំឡឹង២ជី ព្រមទាំងបន្តោងខ្សែប្លាទីនដាំបន្តោងពេជ្រមួយខ្សែ តំលៃជាង៣ពាន់ដុល្លា ចិញ្ចៀនពេជ្រមួយវង់មានតំលៃ៣.៦០០ដុល្លា ក្រវិលពេជ្រមួយគូមានតំលៃ១.៨២០ដុល្លា ខ្សែដៃប្លាទីនមួយខ្សែមួយតំឡឹងតំលៃ១.៣០០ដុល្លា ខ្សែដៃមាស២ខ្សែមានតំលៃ១.៩២០ដុល្លា ចិញ្ចៀន៣វង់មានតំលៃ៤៦០ដុល្លា មាសកាណាឌីយ៉ាមួយដុំមានតំលៃ៩៨០ដុល្លា ។ ខ្លួនសូមបញ្ជាក់ថា នៅពេលខ្លួនដឹងខ្លួនឡើង ខ្លួនបានឃើញដបទឹកសុទ្ធកាត់ជាពីរកំណាត់ដាក់ថ្នាំសណ្តំបណ្តាលឱ្យសមាជិកក្នុងគ្រួសាររបស់ខ្លួន ដែលដេកនៅក្នុងកាណូតទាំង៩នាក់ ដេកលក់មិនដឹងខ្លួនទាំងអស់គ្នា ។ ហើយនៅថ្ងៃទី០៧-១២-២០០៧ ក្រុមរបស់ឈ្មោះ ស្លេម៉ាន មានគ្នាចំនួន៥នាក់បានមកដើរក្បែរទូករបស់ខ្លួន លុះនៅពេលយប់ឡើង ទើបមានការបាត់បង់ទ្រព្យសម្បត្តិរបស់ខ្លួនតែម្តង ។ រហូតដល់ព្រឹកឡើងសមត្ថកិច្ចចាប់ខ្លួនអ្នកដែលលួចសំភារៈរបស់ខ្លួនបានចំនួន២នាក់ ចំណែកបក្សពួកវា៣នាក់ទៀតគេចខ្លួនបាត់ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខៈ៤៩(ក្រ៥) ចុះថ្ងៃទី២៥-៩-២០០៨ របស់សាលាដំបូងក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ផ្តន្ទាទោសៈ

[redacted] ស្លេម៉ាន ភេទប្រុស អាយុ៣០ឆ្នាំ

[redacted] មូស្លីម ភេទប្រុស អាយុ២២ឆ្នាំ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់៥ឆ្នាំ(ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ពីបទៈប្លន់(លួចមានគួកន) ប្រព្រឹត្តនៅក្រុម៧ ភូមិ៣ សង្កាត់ជ្រោយចង្វា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨-១២-២០០៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-ទុកសិទ្ធិឱ្យដើមបណ្តឹងឈ្មោះ [redacted] សារីសំ ប្តឹងទាមទារសំណងរដ្ឋប្បវេណី នៅពេលក្រោយ ។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៩-៩-២០០៨ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៥-៩-២០០៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស្លេម៉ាន [redacted] មូស្លីម មេធាវីការពារជនជាប់ចោទលោក [redacted] នារាកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

-បានឃើញរបាយការណ៍ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

-បានឃើញសេចក្តីសន្និដ្ឋាន ចុះថ្ងៃទី២៤-៨-២០០៩ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាសួរយោបល់តំណាងមហាអយ្យការពីនីតិវិធី

-តំណាងមហាអយ្យការមិនយល់ទាស់នឹងនីតិវិធី

-ប្រធានក្រុមប្រឹក្សាធ្វើសេចក្តីសង្ខេបរឿង



Scanned with CamScanner

-ឈ្មោះ [redacted] ម្ញូស្លីម ឆ្លើយថា: ខ្លួនលួចប្រេងតែ៣កានទេ ។ សមត្ថកិច្ចចាប់ខ្លួននៅផ្ទះ មុនដំបូងខ្លួនទៅនេសាទត្រីទេ ខ្លួនគ្មានបំណងលួចប្រេងគេទេ ខ្លួនប្ដឹងឧទ្ធរណ៍ដោយតុលាការដាក់ទោសខ្លួនច្រើនពេក ។ ខ្លួនសំណូមពរសុំឱ្យបន្ធូរបន្ថយទោស ។

-តំណាងមហាអយ្យការសន្និដ្ឋានថា: ជនជាប់ចោទបានឆ្លើយសារភាពហើយ ហេតុនេះសុំឱ្យតម្កល់សាលក្រមសាលាដំបូងដដែល និង សុំឱ្យឃុំខ្លួនជនជាប់ចោទនេះជាបន្ត ។

-មេធាវីការពារជនជាប់ចោទ សន្និដ្ឋានថា: ចំពោះរឿងនេះ ខ្លួនសំណូមពរសុំឱ្យក្រុមប្រឹក្សាពិចារណាលើសំណូមពររបស់កូនក្ដីខ្លួន ព្រោះការអន្តរាយតិចតួចណាស់ ហើយកូនក្ដីខ្លួនទើបតែប្រព្រឹត្តជាលើកទី១ គឺសុំឱ្យសំរាលទោស ដល់កូនក្ដីខ្លួន ។

## សាលាឧទ្ធរណ៍

-យល់ឃើញថា: ពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៤-១០-២០០៨ របស់ឈ្មោះ [redacted] ម្ញូស្លីម ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងតាមបញ្ញត្តិមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា: តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ម្ញូស្លីម និងឈ្មោះ [redacted] ស្លេម៉ាន បានជិះទូកទៅលួចយកប្រេងម៉ាស៊ូតនៅលើផែបូមខ្សាច់ ហើយបានយកប្រេងនេះទៅលក់ឱ្យឈ្មោះ [redacted] ស្មុះអ៊ីអ៊ី តែឈ្មោះនេះពុំទិញ ក៏បានទុកប្រេងម៉ាស៊ូតចំនួន៣ធុងនៅផ្ទះរបស់ឈ្មោះ [redacted] ស្មុះអ៊ីអ៊ី ហើយត្រូវដើមបណ្ដឹងឈ្មោះ [redacted] សារីម៉ ឃើញក៏ប្ដឹងសមត្ថកិច្ចចាប់ខ្លួនជនជាប់ចោទទាំងពីរតែម្ដង ។

-យល់ឃើញថា: មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ម្ញូស្លីម ពីបទ:ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៨-១២-២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-យល់ឃើញថា: រឿងក្ដីនេះសាលាដំបូងក្រុងភ្នំពេញបានធ្វើការអង្កេត និង លើកយកភស្តុតាងមកសំអាងជូនសព្វគ្រប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដូចនេះសាលាឧទ្ធរណ៍ពុំបាច់លើកយកសំអាងហេតុដដែលនេះ មកបញ្ជាក់ជាថ្មីទៀតទេ ។

-យល់ឃើញថា: សាលក្រមព្រហ្មទណ្ឌលេខ:៤៥(ក្រ៩) ចុះថ្ងៃទី២៥-៩-២០០៨ របស់សាលាដំបូងក្រុងភ្នំពេញដែលសំរេចសេចក្ដីមកនេះ មានលក្ខណ:ត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការដដែល ។

## ហេតុដូច្នេះនិងវិនិច្ឆ័យសេចក្ដី

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៤-១០-២០០៩ របស់ឈ្មោះ [redacted] ម្ញូស្លីម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ:៤៥(ក្រ៩) ចុះថ្ងៃទី២៥-៩-២០០៨ របស់សាលាដំបូងក្រុងភ្នំពេញទុកជាបានការដដែល ។



Scanned with CamScanner

៣-សំរេចឃុំខ្លួនឈ្មោះ[redacted]ម្ល៉ឹម ជាបន្ត ។

៤-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និង មេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្ដឹង បើកផ្លូវប្ដឹងតវ៉ា តាមកំណត់ច្បាប់ ។/.

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។/.

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] [redacted] | ហត្ថលេខ[redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី 06 ខែ 6 ឆ្នាំ២០១៤
ក្រឡាបញ្ជី

[redacted]

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]



Scanned with CamScanner